ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
គណៈកម្មាធិការជាតិ សុខភាព
និងសុវត្ថិភាពការងារ
លេខ ០១០/១៨ គ.ជ.ស.ក

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតក្រុមប្រឹក្សាពិគ្រោះយោបល់គម្រោងលើកកម្ពស់ស្តង់ដាសុខភាព និងសុវត្ថិភាពការងារក្នុងវិស័យសំណង់នៅកម្ពុជា

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានគណៈកម្មាធិការជាតិសុខភាព និងសុវត្ថិភាពការងារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១៤-លោក **នា ធឿន** ប្រធាននាយកដ្ឋានសុវត្ថិភាព និងសន្តិសុខ

នៃមេហ្គា អាសិតមេនេចមេន សមាជិក

១៥-លោក **មីសែល ភាសាញ** ប្រធានគណៈកម្មាធិការវិស័យអចលនទ្រព្យ

នៃសមាគមសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា សមាជិក

១៦-លោក **ម៉ម សុថារិទ្ធ** នាយកក្រុមហ៊ុន រីនកូ ត្រេឌីង សមាជិក

១៧-លោក **ឡើន ឡើត** ក្រុមហ៊ុន CMED Construction Co.,Ltd សមាជិក

១៨-លោក **ដួន ទិចិត្រសីលា** ក្រុមហ៊ុន Daun Penh Construction Co.,Ltd សមាជិក

១៩-លោក **ពិន វ៉ាឌុច** ក្រុមហ៊ុនកូមិនខ្មែរ សមាជិក

**គ. តំណាងភាគីសហជីព**

២០- លោក **សុខ គីន** ប្រធានសហព័ន្ធសហជីពកម្មករសំណង់

និងព្រៃឈើកម្ពុជា សមាជិក

២១-លោក **វ៉ាត់ រ័ត្នមុនី** ប្រធានសហព័ន្ធសហជីពការងារសំណង់កម្ពុជា សមាជិក

២២-លោក **ម៉ៃ សុភ័ត្រា** មន្ត្រីសហភាពសហជីពកម្ពុជា សមាជិក

២៣-លោកស្រី **អេន ឆេងឡាង** អនុប្រធានសហភាពចលនាកម្មករកម្ពុជា សមាជិកា

២៤-លោក **សយ សីហា** អគ្គលេខាធិការសហព័ន្ធសហជីពកម្មករសំណង់

និងព្រៃឈើ សមាជិក

២៥-កញ្ញា **វណ្ណៈ ស្រីនិច** មន្ត្រីសហព័ន្ធសហជីពការងារកម្មករសំណង់ សមាជិកា

**ឃ. តំណាងអង្គការដៃគូ**

២៦-លោក **ទុន សោភ័ណ** អ្នកសម្របសម្រួលថ្នាក់ជាតិ

នៃអង្គការអន្តរជាតិខាងការងារ សមាជិក

២៧-លោក **Sho Sudo** អ្នកគ្រប់គ្រងគម្រោងសុខភាព និងសុវត្ថិភាពការងារ

នៃអង្គការអន្តរជាតិខាងការងារ សមាជិក

២៨-លោកស្រី **ប៉ោ ដួខ** អ្នកសម្របសម្រួលគម្រោងសុខភាព និងសុវត្ថិភាពការងារ

នៃអង្គការអន្តរជាតិខាងការងារ សមាជិកា

២៩-តំណាងអង្គការសុខភាពពិភពលោក (WHO)) សមាជិក

៣០-តំណាងអង្គការអាហ្វីដា (APHEDA) សមាជិក

៣១-តំណាងអង្គការឃែរកម្ពុជា (CARE) សមាជិក

៣២-តំណាងអង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី(LSCW) សមាជិក

៣៣-តំណាងសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍(CWPD) សមាជិក

- បានឃើញអនុក្រឹត្យលេខ២៣៧ អនក្រ.បក ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិសុខភាព និងសុវត្ថិភាពការងារ
- សេចក្តីសម្រេចលេខ០០១ គជសក ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការរៀបចំសមាសភាពនៃគណៈកម្មាធិការជាតិសុខភាព និងសុវត្ថិភាពការងារ
- យោងតាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

### ប្រការ ១.-

ត្រូវបានបង្កើតក្រុមប្រឹក្សាពិគ្រោះយោបល់គម្រោងលើកកម្ពស់ស្តង់ដាសុខភាព និងសុវត្ថិភាពការងារក្នុងវិស័យសំណង់នៅកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម៖

### ក. តំណាងភាគីរដ្ឋាភិបាល

| | | | |
|---|---|---|---|
| ១-ឯកឧត្តមវេជ្ជ. | **ហ៊ុយ ហានសុខ** | រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ប្រធាន |
| ២-លោកជំទាវ | **ខៃ្វ សុភាព** | អគ្គលេខាធិការរងនៃគណៈវិស្វករកម្ពុជា | សមាជិកា |
| ៣-លោកជំទាវ | **ជា សុខនី** | អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ | សមាជិកា |
| ៤-លោកជំទាវ | **ម៉ៅ ធីតា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានការងារ | សមាជិកា |
| ៥-ឯកឧត្តម | **ឡេង តុង** | ប្រធាននាយកដ្ឋានពេទ្យការងារ | សមាជិក |
| ៦-ឯកឧត្តមវេជ្ជ. | **យី កន្និដ្ឋា** | អនុប្រធាននាយកដ្ឋានពេទ្យការងារ | សមាជិក |
| ៧-ឯកឧត្តម | **ស៊ុំ សោភ័ណ** | នាយករងបេឡាជាតិរបបសន្តិសុខសង្គម | សមាជិក |
| ៨-លោក | **ប៊ី ពិទូរ្យ** | អគ្គនាយករងឧស្សាហកម្មនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ៩-លោក | **ជីវ ស៊ីវផេង** | ប្រធាននាយកដ្ឋានស្រាវជ្រាវបច្ចេកទេសសំណង់ នៃក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១០-លោក | **តាន់ ធីរ៉ា** | ប្រធាននាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធសាធារណៈ នៃក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១១-លោក | **ជា ឡេង** | ប្រធាននាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នៃក្រសួងបរិស្ថាន | សមាជិក |
| ១២-លោក | **គីម លំអងបុព្វតា** | អនុប្រធាននាយកដ្ឋានគោលនយោបាយ និងសម្របសម្រួលហិរញ្ញប្បទានសហប្រតិបត្តិការ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១៣-លោកវេជ្ជ. | **សុខ ស្រ៊ុន** | ប្រធាននាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាល | សមាជិក |

### ខ. តំណាងភាគីនិយោជក

៣៤-តំណាងទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍(AFD) សមាជិក

**ប្រការ ២.-**

ក្រុមប្រឹក្សាពិគ្រោះយោបល់នេះមានភារកិច្ចៈ

- ត្រួតពិនិត្យកម្មវិធី និងពិភាក្សាអំពីលទ្ធផល ព្រមទាំងដើរតួជាអ្នកគិតគូរដើម្បីគាំទ្រការអនុវត្តគម្រោង
- ពិនិត្យឡើងវិញនូវវឌ្ឍនភាពនៃការអនុវត្តគម្រោង អនុម័តលើផែនការការងារ និងធនធានប្រចាំឆ្នាំ និងការផ្លាស់ប្តូរ ឬការកែសម្រួលណាមួយបើចាំបាច់
- ប្រមូលផ្តុំក្រុមការងារស្នូល ឬបុគ្គលដើម្បីសម្របសម្រួល និងធ្វើការយ៉ាងជិតស្និទ្ធជាមួយអង្គការអន្តរជាតិខាងការងារ អំពីសកម្មភាពគម្រោងដែលបានជ្រើសរើស
- ផ្តល់អនុសាសន៍ជាយុទ្ធសាស្ត្រ និងការកែតម្រូវសកម្មភាពទៅលើបញ្ហាប្រឈមរបស់គម្រោង និងបញ្ហាផ្សេងៗ ដែលកំពុងកើតឡើង
- ជូនដំណឹងទៅអង្គការអន្តរជាតិខាងការងារ ពីការអភិវឌ្ឍន៍គោលនយោបាយ និងសេចក្តីណែនាំថ្មីៗ ដែលពាក់ព័ន្ធនឹងគម្រោង
- លើកកម្ពស់តម្លៃនៃគម្រោងនៅក្នុងបណ្តាញរបស់ខ្លួន ដើម្បីស្វែងរកនិងបង្កើត ការរួមបញ្ចូលគ្នាជាមួយនឹងគំនិតផ្តួចផ្តើម និងគម្រោងស្រដៀងគ្នាដោយម្ចាស់ជំនួយដទៃទៀត
- ភ្ជាប់លទ្ធផលគម្រោងជាមួយនឹងការអភិវឌ្ឍគោលនយោបាយនានាដូចជាៈ ការផ្តួចផ្តើមឱ្យមានការសម្របសម្រួលជំហានបន្ទាប់ ដើម្បីជានាសកម្មភាពបន្តបន្ទាប់
- បង្កើតការគាំទ្រស្ថាប័នសម្របសម្រួល ការទទួលយក ការចម្លង និរន្តរភាព និងយន្តការនានានៃកិច្ចដំណើរការ និងលទ្ធផលដែលទាក់ទងនឹងសកម្មភាពរបស់គម្រោង
- ធ្វើសកម្មភាពលើបញ្ហាពាក់ព័ន្ធផ្សេងទៀតដែលកើតឡើងពីការអនុវត្តគម្រោងដែលបានព្រមព្រៀងគ្នាក្នុងចំណោមសមាជិកស្នូលទាំងអស់។

**ប្រការ ៣.-**

ក្រុមប្រឹក្សាពិគ្រោះយោបល់គម្រោងលើកកម្ពស់ស្តង់ដាសុខភាព និងសុវត្ថិភាពការងារក្នុងវិស័យសំណង់មានលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ ដែលមានទីតាំងនៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយប្រើមន្ត្រីមានក្របខណ្ឌស្រាប់ ដើម្បីជាជំនួយការក្នុងការសម្របសម្រួលការងារ។ សមាសភាពនេះ ត្រូវបានប្រគល់ភារកិច្ចបន្ថែមលើមុខងារបច្ចុប្បន្នដូចមានរាយនាមខាងក្រោមៈ

| | | | |
|---|---|---|---|
| ១-លោកជំទាវ | **ជា សុខនី** | អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ | ប្រធាន |
| ២-លោកជំទាវ | **ម៉ៅ ធីតា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានការងារ | សមាជិកា |
| ៣-លោក | **ភូច ម៉ុនធឿន** | ប្រធានការិយាល័យអាស៊ានអូស្តណេត នៃនាយកដ្ឋានពេទ្យការងារ | សមាជិក |
| ៤-កញ្ញាវេជ្ជ. | **ស្គុន រដ្ឋា** | ប្រធានការិយាល័យស្ថិតិ និងទំនាក់ទំនងខាងក្រៅ នៃនាយកដ្ឋានពេទ្យការងារ | សមាជិកា |
| ៥-លោក | **ខៀវ ម៉ុនគាខ** | មន្ត្រីលេខាធិការដ្ឋានអេដស៍ | សមាជិក |

មន្ត្រីសម្របសម្រួលគម្រោងរបស់អង្គការអន្តរជាតិខាងការងារ(NPC)នឹងធ្វើការ ជាមួយលេខាធិការដ្ឋាន។

## ប្រការ ៤.-

លេខាធិការដ្ឋាននេះមានភារកិច្ចៈ

- ជួយសម្រួលការងារប្រធានក្រុមប្រឹក្សាពិគ្រោះយោបល់គម្រោង
- ប្រមូល និងចងក្រងគោលនយោបាយ គោលការណ៍ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងព័ត៌មានចាំបាច់ពីភាគីពាក់ព័ន្ធ
- រក្សា និងធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាពិគ្រោះយោបល់គម្រោង
- បង្កើត និងរក្សាទុកនូវកាលវិភាគសកម្មភាព ឬកម្មវិធីការងារ
- ផ្គត់ផ្គង់ឯកសារសារតាផ្សេងៗ សេវាសិក្សាស្រាវជ្រាវ ឬព័ត៌មានដទៃទៀតដែលចាំបាច់ ដើម្បីរៀបចំប្រធានបទសម្រាប់ការពិភាក្សា
- រៀបចំធ្វើការសិក្សា ឬស្រាវជ្រាវដោយផ្ទាល់ ឬតាមរយៈការឧបត្ថម្ភគម្រោង
- រៀបចំចាត់ចែងការប្រជុំ និងផ្គត់ផ្គង់បរិក្ខារសម្រាប់ការប្រជុំក្រុមប្រឹក្សាពិគ្រោះយោបល់គម្រោង
- ធ្វើការតាមដានរាល់ការអនុវត្តភារកិច្ចរបស់ក្រុមប្រឹក្សាពិគ្រោះយោបល់គម្រោង
- ប្រមូលព័ត៌មាន និងវិភាគទិន្នន័យស្តីពីសុខភាព និងសុវត្ថិភាពការងារ ជាពិសេសក្នុងវិស័យសំណង់
- រិះរកនូវការអនុវត្តល្អៗ និងមេរៀនដែលទទួលបានពីការកសាងនិងចែករំលែកចំណេះដឹងនានា និងលើកកម្ពស់ការយល់ដឹងនៃគម្រោង ដល់សមាជិកក្រុមប្រឹក្សាពិគ្រោះយោបល់គម្រោង
- រៀបចំសេចក្តីព្រាងនៃការសន្និដ្ឋានចុងក្រោយ និងសេចក្តីសម្រេច ដើម្បីដាក់ជូនរដ្ឋមន្ត្រី
- រៀបចំរបាយការណ៍ ឯកសារផ្សេងៗសម្រេចចុងក្រោយ និងព័ត៌មានផ្សេងៗទៀត ក៏ដូចជាការចែកចាយ
- នូវព័ត៌មានស្តីពីសកម្មភាពរបស់ក្រុមប្រឹក្សាពិគ្រោះយោបល់
- បូកសរុបនិងផ្តល់របាយការណ៍ប្រចាំឆ្នាំស្តីពីសកម្មភាពការងាររបស់ក្រុមប្រឹក្សាពិគ្រោះយោបល់គម្រោង
- រក្សាទំនាក់ទំនងជាមួយសមាជិកនៃក្រុមប្រឹក្សាពិគ្រោះយោបល់គម្រោង
- សកម្មក្នុងការផ្តើមគំនិតលើកជារបៀបវារៈទៅពិភាក្សា ជាមួយប្រធានក្រុមប្រឹក្សាពិគ្រោះយោបល់គម្រោង
- សហការ និងសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធ អង្គការនិយោជក អង្គការកម្មករនិយោជិតដើម្បីលើកកម្ពស់ការយល់ដឹងអំពីសុខភាព និងសុវត្ថិភាពការងារ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានប្រគល់ជូន។

## ប្រការ ៥.-

ក្រុមប្រឹក្សាពិគ្រោះយោបល់គម្រោង ត្រូវរៀបចំកិច្ចប្រជុំយ៉ាងតិច ៤ (បួន) លើកក្នុង១(មួយ)ឆ្នាំយ៉ាងតិច។ សមាជិកសមាជិកានៃក្រុមប្រឹក្សាពិគ្រោះយោបល់គម្រោង ត្រូវចូលរួមប្រជុំតាមការកំណត់និងការអញ្ជើញរបស់ប្រធាន។

## ប្រការ ៦.-

ក្រុមប្រឹក្សាពិគ្រោះយោបល់គម្រោង មានប្រភពធនធានផ្គត់ផ្គង់ ដោយថវិកាជំនួយឧបត្ថម្ភពីអង្គការអន្តរជាតិខាងការងារ និងមានសិទ្ធិប្រើប្រាស់ថវិកាដែលទទួលបានតាមរយៈគណនីរបស់ខ្លួនឱ្យមានប្រសិទ្ធភាព និងតម្លាភាពក្នុងការបំពេញភារកិច្ចរបស់ខ្លួន ដោយគោរពទៅតាមនីតិវិធីច្បាប់ និងបទបញ្ញានានាទាក់ទងនឹងការគ្រប់គ្រងហិរញ្ញវត្ថុ។

**ប្រការ ៧.-**

នាយកខុទ្ទកាល័យ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអគ្គនាយកដ្ឋានការងារ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គម ប្រធានអង្គភាពពាក់ព័ន្ធទាំងអស់ និងសាមីខ្លួនមានភារកិច្ចអនុវត្តរៀងៗខ្លួនតាមសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ច័ន្ទ ៤ កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ២០១៨

**រដ្ឋមន្ត្រី និងជាប្រធាន**

**គណៈកម្មាធិការជាតិសុខភាព និងសុវត្ថិភាពការងារ**

**អ៊ិត សំហេង**

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- គ្រប់អង្គភាពក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- គ្រប់សមាគមនិយោជក
- គ្រប់សហព័ន្ធសហជីព
- ដូចប្រការ ៧
- ឯកសារ-កាលប្បវត្តិ